# «រូបពីរ» វិមានរំឭកគុណអ្នកអនិច្ចកម្មក្នុងចម្បាំងធំ

«រូបពីរ» ជាពាក្យខ្មែរហៅសំដៅដល់ស្តូបសាងសង់ឡើងដើម្បីរំឭកគុណដល់វីរភាពយុទ្ធជនខ្មែរ និងបារាំង ដែលពលីជីវិតក្នុងសង្គ្រាមកាលពីឆ្នាំ១៩១៤-១៩១៨។ តាមរយៈឯកសាររាជកិច្ចរាជការ[១] បោះពុម្ពឆ្នាំ១៩២៥ ហៅស្តូបនេះថា «វិមានរំឭកគុណដល់អ្នកដែលទទួលអនិច្ចកម្មក្នុងចម្បាំងធំ (ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨)» ហើយមានចារឹកពាក្យបារាំងថា *"Monument aux Morts"* (រូបលេខ១)។ អតីតស្តូបនេះ កសាងឡើងនៅម្តុំរង្វង់មូលគល់ស្ពានជ្រោយចង្វារត្រើយខាងលិច ក្នុងរាជធានីភ្នំពេញ ពោលគឺស្ថិតនៅពុំឆ្ងាយពីស្ថានទូតបារាំងឡើយ។ ប៉ុន្តែក្នុងសម័យសង្គ្រាមទសវត្សទី១៩៧០ គេបានបំផ្លាញស្តូបខាងលើរហូតក្លាយជាបំណែកៗ ហើយថ្មីៗនេះរាជរដ្ឋាភិបាលគ្រោងនឹងរៀបចំស្ថាបនាឡើងវិញទុកជានិមិត្តរូបនៃសាមគ្គីភាពរវាងបារាំង និងកម្ពុជា។[២]



*រូបលេខ១ "រូបពីរ" ឬស្តូបរំឭកគុណអ្នកអនិច្ចកម្មក្នុងសង្គ្រាម (ប្រភព៖ delcampe.net)*

[១] ពាក្យដើមសរសេរជា «រាជកិច្ចរាជ្ជការ»

[២] គេហទំព័រនៃទីស្តីការគណៈរដ្ឋមន្ត្រី ផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាការពិតតាមរយៈប្រវត្តិសាស្ត្រឱ្យដឹងថា សង្គ្រាមរវាងមហាអំណាចធំៗក្នុងពិភព លោកកាលពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨ ឬគេហៅថា «សង្គ្រាមលោកលើកទី១»[៣] ពលរដ្ឋនៃប្រទេសស្ថិតក្រោមអាណាព្យាបាលរបស់មហាអំណាចទាំងអស់ ត្រូវគេកែនបញ្ជូនឱ្យទៅជួយច្បាំងដែរ (រូបលេខ២)។[៤] គ្រានោះកម្ពុជាដែលស្ថិតក្រោមអាណាព្យាបាលបារាំង បានបញ្ជូនយុទ្ធជនចំនួន១៨៨នាក់ទៅចូលច្បាំង[៥] ហើយខ្លះបានបាត់បង់ជីវិត ខ្លះរបួសធ្ងន់ស្រាលដោយអំណាចសង្គ្រាម។ ក្នុងបំណងសងគុណបំណាច់ដ៏ធំធេងនៃពលីកម្មនេះ នៅរវាងឆ្នាំ១៩២២ គេបានចាប់ផ្ដើមស្ថាបនាចារឈ្មោះយុទ្ធជនទាំង១៨៨នាក់ ទុកជាវិមានរំឭកដែលខ្មែរទូទៅតែងហៅថា«រូបពីរ»។[៦] វិមាននេះស្ថាបនារួចស្រេច ហើយសម្ពោធយ៉ាងឱឡារិកនៅក្នុងខែមីនា ឆ្នាំ១៩២៥។



រូបលេខ២ រូបថតនៃយុទ្ធជនកម្ពុជាមួយចំនួនដែលចូលច្បាំងក្នុងសង្គ្រាមលោកលើកទី១ (ប្រភពរូប៖ ?)

---

[៣] ពាក្យ «សង្គ្រាមលោកលើកទី១» ចាប់ផ្ដើមប្រើក្នុងរវាងឆ្នាំ១៩៣៩

[៤] *Penny Edwards, 2006: 433* និងក្រសួងអប់រំយុវជននិងកីឡា ២០១៧: ២២

[៥] បុនរ្ទ័ចូវិមានដែរសោងក្នុងក្រុងកម្ពុជាធិបតី ១៩២៥: ៦១

[៦] ព្រាប ចាន់ម៉ារ៉ា ២០១៣-២០១៤: ៩០-៩២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

បើតាមសេចក្ដីអធិប្បាយក្នុងឯកសាររាជកិច្ចរាជការឆ្នាំ១៩២៥ បានពិពណ៌នាទិដ្ឋភាពពិធីសម្ពោធវិមានខាងលើថា មានភាពឱឡារិកគគ្រឹកគគ្រេងក្រៃលែង ដ្បិតមានព្រះរាជវត្តមានរបស់ **ព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ព្រះរាជានុភោដ្ឋ** និង **ព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ មុនីវង្ស ព្រះបរមខត្តិយភោដ្ឋ** ព្រមទាំងថ្នាក់ដឹកនាំជាន់ខ្ពស់បារាំងគឺលោក ហ្វ្រង់ស័រ បូដួរ៉ាំង (François Baudoin) អគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន ក៏ដូចជាព្រះវត្តមាន និងវត្តមានព្រះសង្ឃ មន្ត្រីអាណាព្យាបាលបារាំង កងទាហានជើងទឹក-ជើងគោកបារាំង ក្រុមកាំភ្លើងធំ តំណាងក្រុមទាហានពីព្រៃនគរ ជាពិសេសគឺមានក្រុមភ្លេង-របាំ និងជាតិសាសន៍ផ្សេងៗក្នុងកម្ពុជា (រូបលេខ៣-៦)។[៧]




រូបលេខ៣-៤ ព្រះរាជវត្តមានព្រះមហាក្សត្រ ថ្នាក់ដឹកនាំបារាំង និងព្រះសង្ឃក្នុងពិធីសម្ពោធស្តូបរូបពីរ (ប្រភព៖ yosothor.org)




រូបលេខ៥-៦ ក្រុមរបាំ និងភ្លេងក្នុងពិធីសម្ពោធស្តូបរូបពីរ (ប្រភព៖ yosothor.org)

[៧] បុន្យឆ្លងវិមានដែរសោងក្នុងក្រុងកម្ពុជាធិប្តី ១៩២៥: ៧៩-៨៨

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

វិមានរំឭកគុណយុទ្ធជនខ្មែរ-បារាំង ឬគេហៅខ្លីថា «រូបពីរ» ស្ថាបនាឡើងអំពីថ្ម និងលម្អដោយចម្លាក់ស្និតយ៉ាងវិចិត្រក្រៃលែង។ វិមាននេះសង់ខ្ពស់ត្រដែត ហើយមានបីផ្នែក គឺនៅផ្នែកខាងលើ និងផ្នែកកណ្តាល គេសាងឡើងអំពីលោហៈ។ នៅផ្នែកលើបំផុតនោះ គេតម្កល់រូបមនុស្សប្រុសពីរនាក់ ដែលម្នាក់រាងខ្ពស់ជាទាហានបារាំង ឯម្នាក់ទៀតតូចជាងនោះបន្តិចជាទាហានខ្មែរ។[៨] រីឯនៅផ្នែកកណ្តាល មានសណ្ឋានមូលស្រដៀងនឹងអគ្គ(ខ្លួន) នៃចេតិយ ហើយមានឆ្លាក់រូបមនុស្សប្រុសស្រី ទាំងក្មេងទាំងចាស់ក្នុងកាយវិការផ្សេងៗព័ទ្ធជុំវិញផង។ ចំណែកផ្នែកក្រោម គេសាងឡើងអំពីថ្ម មានរាងបួនជ្រុង ហើយនៅមុមជ្រុងនីមួយៗ គេលម្អដោយរូបក្បាលដំរីខាងក្រោម និងក្បាលនាគខាងលើ។ ប៉ុន្តែរូបក្បាលដំរី និងក្បាលនាគទាំងអស់នេះ គេសាងអំពីលោហៈ ហើយនៅផ្ទៃថ្មគេចារឈ្មោះយុទ្ធជនចំនួន១៨៨នាក់។ ដោយឡែកនៅជ្រុងទាំងបួននៃខឿនជុំវិញ គេតម្កល់រូបតោដែលសាងអំពីលោហៈដែរ។ ផុតពីនោះមកគឺជាបរិវេណសួន ដែលគេឃើញមានតម្កល់ដាក់តម្កល់កាំភ្លើងធំនៅតាមជ្រុងនីមួយៗ (រូបលេខ៧)។



***រូបលេខ៧ ទិដ្ឋភាពវិមានរំឭកគុណខ្មែរ-បារាំង "រូបពីរ" ថតចុងទសវត្សទី២០ (ប្រភព៖ quaibranly.fr)***

---

[៨] ព្រាប ចាន់ម៉ារ៉ា ២០១៣-២០១៤: ៩០-៩២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

លុះចូលដល់របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) គេបានបំផ្លាញវិមានរំឭកគុណយុទ្ធជនខាងលើឱ្យអន្តរាយ នៅសល់តែបំណែកលោហៈបែកពីផ្នែកកណ្ដាលនៃស្តូប ក្បាលរំដី ក្បាលនាគ និងតោ។ បំណែកទាំងនោះសរុបមានចំនួន៧ដុំ ហើយធ្លាប់បានចុះបញ្ជី និងរក្សាទុកនៅសារមន្ទីរជាតិកម្ពុជាដូចជា បំណែកចម្លាក់នៃផ្នែកកណ្ដាលរបស់ស្តូប (*Ga.5929*) (រូបលេខ៨) ក្បាលនាគ (*Ga.5930*) (រូបលេខ៩) រូបតោ (*Ga.5978*) (រូបលេខ១០) និងបំណែកក្បាលរំដីទាំងបួនទិស (លេខ *Ga.5927.1, Ga.5927.2, Ga.5927.3* និង *Ga.5927.4*) (រូបលេខ១១)។




*រូបលេខ៨-១១ បំណែកផ្សេងៗនៃវិមានរូបពីរក្នុងបញ្ជីសារមន្ទីរជាតិកម្ពុជា (ប្រភព៖ **cambodiamuseum.info**)*

ចំពោះបំណែកនៃផ្នែកកណ្ដាលរបស់ស្តូប ប្រសិនបើពិនិត្យលម្អិតគេឃើញចម្លាក់នៅលើផ្ទៃលោហៈនោះគួរឱ្យចាប់អារម្មណ៍ពន់ពេកណាស់ ពោលគឺទាំងទឹកដៃសិល្បៈនិងខ្លឹមសារ។ តាមរយៈរូបលេខ១២ ដែលគេថតតាំងពីសម័យបារាំង គឺបង្ហាញឱ្យឃើញថាម្ខាងនោះមានរូបស្ត្រីម្នាក់ ក្នុងដៃមានកាន់កូនតូច ឈរបន្ទន់ជង្គង់ឈ្ងោកមុខ ហាក់ដូចជាហុចទៅឱ្យនរណាម្នាក់នៅខាងមុខ។ ប៉ុន្តែនៅខាងក្រោយខ្នងស្ត្រីនោះ មានមនុស្សពីរនាក់កំពុងឈរបាំងក្ងស់ឱ្យ។ ចំណែករូបលេខ១៣-១៥ ជាបំណែកធ្លាប់រក្សានៅសារមន្ទីរជាតិកម្ពុជាគឺជារូបបន្តគ្នា។ ប៉ុន្តែផ្នែកម្ខាងនៃរូបលេខ១៣ គេឃើញចលនារូបផ្ទុយគ្នា ពោលគឺខាងឆ្វេងជារូបស្ត្រីពរកូន ឯរូបខាងស្តាំទំនងជារូបបុរសពីរនាក់ កំពុងបាំងក្ងស់ឱ្យមនុស្សម្នាក់ទៀតនៅខាងមុខ ដែលមើលឃើញក្នុងរូបលេខ១៤ គឺជាមនុស្សស្រីស្លៀកសំពត់ និងមានលម្អកងលើកជើងពាក់ជើងផង។ នៅខាងមុខស្ត្រីនោះ(រូបលេខ១៥) គឺមានស្ត្រីម្នាក់

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*ទៀតលុតជង្គង់ ហើយមានបុរសម្នាក់កំពុងក្រាបសំពះនៅខាងមុខ ហុចដើងពានផ្លៃឈើជូនស្ត្រីនោះ។ រីឯរូបកូនក្មេងដែលស្ត្រីម្នាក់កាន់ក្នុងរូបលេខ២១៣ គឺធ្លាក់នៅផ្នែកខាងលើនៃបុរសកំពុងសំពះនេះ។ ដូច្នេះរូបលើតួស្តូបរូបពីរ គឺធ្លាក់ដេញបន្តគ្នាជុំវិញ។ ប៉ុន្តែគេពិបាកសន្និដ្ឋានថា ខ្លឹមសារនៃចម្លាក់ទាំងនេះសិល្បករចង់រៀបរាប់ប្រធានបទអ្វីខ្លះឡើយ។*



*រូបលេខ២១២*



*រូបលេខ២១៣*



*រូបលេខ២១៤*



*រូបលេខ២១៥*

*ដោយឡែកចំពោះបំណែកក្បាលដំរីទាំងបួន គេសង្កេតឃើញបំណែកពីរទំនងនៅពេញលក្ខណៈដើម ដ្បិតមានទំហំធំ កម្ពស់ប្រហែល៣ម៉ែត្រ តែគេសាងឡើងត្រឹមមួយកំណាត់ក្បាល និងជើងមុខប៉ុណ្ណោះ ដោយមានប្រមោយត្រកងផ្កាឈូក និងភ្នក់វែងៗដូចៗគ្នា (រូបលេខ២១៦)។ បំណែកពីរផ្សេងទៀត នៅសល់តែក្បាល និងភ្លុក ពោលគឺបាក់បាត់ប្រមោយ និងជើងមុខ (រូបលេខ២១៧)។ រីឯក្បាលនាគ និងគោគឺនៅមានលក្ខណៈពេញលេញ ពុំបែកបាក់ខូចខាតខ្លាំងឡើយ។ ប៉ុន្តែបន្ទាប់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បង្ហើបប្រាប់លោកប្រធានាធិបតីបារាំង អំពីការរកឃើញរូបសំណាកមិត្តភាពកម្ពុជា-បារាំង ហើយគ្រោងនឹងសាងសង់រូបសំណាកនោះឡើងវិញនៅមុខស្ថានទូតបារាំងក្នុងរាជធានីភ្នំពេញ[៩] នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២២ សារមន្ទីរជាតិភ្នំពេញបានប្រគល់បំណែកទាំង៧ ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីផ្គុំ និងសាងសង់ស្តូបអនុស្សាវរីយ៍មិត្តភាពកម្ពុជា-បារាំងឡើងវិញ (រូបលេខ២០-២១)។[១០]*

---

*[៩] គេហទំព័រនៃទីស្តីការគណៈរដ្ឋមន្ត្រី ផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២*

*[១០] ដំណឹងផ្សាយលើហ្វេសបុកផេកផ្លូវការសារមន្ទីរជាតិកម្ពុជា ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២២*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*



រូបលេខ១៦-១៩ បំណែកក្បាលដំរី នាគ និងតោនៃស្តូបរូបពីរ កាលរក្សានៅសារមន្ទីរជាតិកម្ពុជា



រូបលេខ២០-២១ សកម្មភាពលើកដាក់ដឹកជញ្ជូនបំណែកផ្សេងៗនៃស្តូបរូបពីរចេញពីសារមន្ទីរជាតិកម្ពុជា ដើម្បីយកទៅរៀបចំជួសជុលផ្គុំកសាងឡើងវិញ (ប្រភពរូប៖ ហ្វេសបុកសារមន្ទីរជាតិកម្ពុជា)

ដូច្នេះជារួមមក អតីតស្តូប ឬវិមានរំឭកគុណយុទ្ធជនពលីកម្មក្នុងសង្គ្រាមលោកលើកទី១ ដែលភាគច្រើនហៅថា "រូបពីរ" គឺបង្ហាញឱ្យឃើញពីទឹកដៃសិល្បៈយ៉ាងល្អ។ មិនតែប៉ុណ្ណោះ វិមាននេះជាកស្តុតាងប្រវត្តិសាស្ត្រកម្ពុជាសម័យអាណាព្យាបាលបារាំង ដែលយុទ្ធជនខ្មែរបានបូជាជីវិតក្នុងការសង្គ្រាមលោកផង និងជានិមិត្តរូបយ៉ាងសំខាន់នៃទំនាក់ទំនងជាមិត្តរបស់បារាំងនិងកម្ពុជា៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង


ក្រសួងអប់រំយុវជននិងកីឡា

២០១៧, *ប្រវត្តិវិទ្យា (សម័យអាណាព្យាបាលបារាំង-ព្រះរាជាណាចក្រទី២)*, ក្រសួងអប់រំយុវជននិងកីឡា, ភ្នំពេញ

គេហទំព័រនៃទីស្ដីការគណៈរដ្ឋមន្ត្រី

«សម្ដេចតេជោ ហ៊ុន សែន អញ្ជើញធ្វើសន្និសីទរួមគ្នាជាមួយប្រធានាធិបតីបារាំង» ផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២

តន វិបុល

២០២២, «មន្ត្រីរដ្ឋាភិបាលនិងអ្នកជំនាញប្រវត្តិសាស្ត្របង្ហាញការគាំទ្រការបង្កើតស្តូបរូបពីរឡើងវិញ» ផ្សាយលើគេហទំព័រកាសែត «ខ្មែរថាមស៍» ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០២២ https://www.khmertimeskh.com/

ព្រាប ចាន់ម៉ារ៉ា

២០១៣-២០១៤, «រូបពីរ», *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ២៩*, ទំ.៩០-៩២, យសោធរ, ភ្នំពេញ

អនាមិក,

១៩២៥, «បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិបិ្ត», *រាជកិច្ចរាជ្ការ*, ទំ.៥៩-១០៧, រោងពុម្ពប្រូតិកតូរ៉ាត់, ភ្នំពេញ

*Penny Edwards*

*2006,* 'The Tyranny of Proximity: Power and Mobility in Colonial Cambodia, 1863–1954', *Journal of Southeast Asian Studies,* Vo. 37, Issue 03, pp 421 - 443


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត